**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ ១៥៦
ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ ២០០៤
**សាលដីកា**
លេខៈ ២៤៩
ចុះថ្ងៃទី០៤ ខែវិច្ឆកា ឆ្នាំ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៤ ខែវិច្ឆកា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ........... ជាប្រធាន
២-លោក ............ ជាចៅក្រម
៣-លោក .............. ជាចៅក្រម
៤-លោក .............. ជាចៅក្រម
៥-លោក ............... ជាចៅក្រមរបាយការណ៍

**ក្រឡាបញ្ជី**

-លោក .................

**តំណាងមហាអយ្យការ**

-ឯកឧត្តម ................ ជាព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ១៦៨(ឈ)ចុះថ្ងៃទី១៨ ខែវិច្ឆកា ឆ្នាំ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៤៣០ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ សសរ(ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣២ឆ្នាំ ជាតិ ខ្មែរ មុខរបរលក់ដីគីមី ទីលំនៅផ្ទះលេខ៥ ផ្លូវ១០៥ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា ក្រុងភ្នំពេញ

មានមេធាវីលោក .............. ។

ចុងចម្លើយឈ្មោះ លគឈ ហៅ លសរជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុសអាយុ៥៣ឆ្នាំ មុខរបរអាជីវករ ទីលំនៅភូមិព្រែកសំរោង ឃុំ-ស្រុកតាខ្មៅ ខេត្តកណ្តាល ។

មានមេធាវីលោក ............ ។

**<u>កម្មវត្ថុបណ្តឹង:</u>** ប្តឹងទាមទារប្រាក់ .

បានឃើញបណ្តឹងសាទុក្ខលេខ៨៥ ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ២០០៨ របស់លោក ............ ជាមេធាវីការពារឱ្យចុងចម្លើយ ប្តឹងមិនសុខចិត្តនិងសាលដីការដ្ឋប្បវេណីលេខ១៦៨(ឈ)ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១៥៦ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៤ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១១-១១-២០០២ របស់ឈ្មោះសសរប្តឹងទារប្រាក់ពីឈ្មោះ លគឈ ហៅលី សារិទ្ធ ដោយសំអាងហេតុថា កាលពីថ្ងៃទី១១-០៨-២០០២ និងថ្ងៃទី១៨-០៩-២០០២ ពុំព្រមសងប្រាក់ចំនួន ៨៥០ដុល្លាអាមេរិក និងប្រាក់បាតចំនួន៥០៥០៤០បាត មកឱ្យខ្លួនរហូតមកដល់សព្វថ្ងៃនេះ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ០៣(ក)ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៣ របស់តុលាការខេត្តកណ្តាល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០២ របស់ដើមចោទឈ្មោះ សសរទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី១៥ ខែ១១ ឆ្នាំ២០០២ របស់ឈ្មោះសសរទុកជាមានសុពលភាពតាមច្បាប់ ។

៣-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី២១ ខែ១១ ឆ្នាំ២០១២ របស់ឈ្មោះលីសារិទ្ធ ហៅលើ គង់ឈុន ទុកជាមានសុពលភាពតាមច្បាប់ ។

៤-បង្គាប់ឱ្យឈ្មោះលីសារិទ្ធ ហៅលើ គង់ឈុន និងប្រពន្ធឈ្មោះហេង មួយខេង សងប្រាក់លថ្លៃទិញដីគីមីចំនួន ៤៧៤.៦៩៥បាត និងការប្រាក់ ៥ភាគរយក្នុងមួយឆ្នាំ គិតពីថ្ងៃជំពាក់ ថ្ងៃទី០២-១០-២០០២ រហូតដល់ពេលសងប្រាក់ និងជំម្ងឺចិត្តចំនួន១.០០០ដុល្លា(មួយពាន់ដុល្លាអាមេរិក)សំណើលើសពីនេះត្រូវលើកចោលចាប់ពីសាលក្រមចូលស្ថាពរតទៅ ។

ក្នុងករណីគ្មានប្រាក់សងគ្រប់ចំនួនទេ ត្រូវរឹបអូសទ្រព្យសម្បត្តិលក់ឡាយឡុង បើរឹងទទឹងត្រូវដាក់គុកបង្ខំដល់រូបរាងកាយ តាមមាត្រា១៣៣នៃច្បាប់ស្តីពីការអនុវត្តសាលក្រមរដ្ឋប្បវេណី ។

៥-បង្គាប់ឱ្យឈ្មោះលី សារិទ្ធ ហៅលគឈ និងប្រពន្ធឈ្មោះហេងមួយខេង បង់ប្រាក់ប្រដាប់ក្តីសរុប ៧.០០០៛ ចំណាយលើពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង១៨០០៛ រង្វាន់ក្រឡាបញ្ជី កាន់ហិបប្រាក់២០០៛ ចំណាយក្នុងកិច្ចការស៊ើបសួរ ៥.០០០៛ ប្រាក់នេះដើមចោទបានបង់រួចហើយ។ហើយឱ្យចុងចម្លើយសងទៅដើមចោទវិញ កាលបើផុតកំណត់ប្តឹងឧទ្ធរណ៍ហើយ បង្គាប់ឱ្យឈ្មោះលី សារិទ្ធ ហៅលគឈ បង់ពន្ធសមាមាត្រមួយភាគរយ នៃប្រាក់ដើមចំនួន ៤៧៤.៦៩៥ បាតស្មើនឹង៤៧៤៦,៩៥បាតដោយបង់ចូលថវិការដ្ឋចំនួន៨០%និងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០% ប្រាក់នេះដើមចោទត្រូវបង់ទុកជាមុនដែរ ទើបឱ្យចុងចម្លើយសងទៅដើមចោទវិញ ។

៦-សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខដើមចោទឈ្មោះ .............(តំណាងផ្ទេរសិទ្ធិ និងកំបាំងមុខចុងចម្លើយឈ្មោះ............ តំណាងផ្ទេះរសិទ្ធិ) ។

បើកផ្លូវប្តឹងទាស់ ១៥ថ្ងៃ និងប្តឹងឧទ្ធរណ៍ពីរខែតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងតវ៉ាចុះថ្ងៃទី១១ខែមីនាឆ្នាំ២០០៣ របស់លោក............ ជាមេធាវីការពារឱ្យចុងចម្លើយ ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ០៣ (ក) ចុះថ្ងៃទី២៩ខែមករា ឆ្នាំ២០០៣ របស់តុលាការខេត្តកណ្តាល ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៤(ក) ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៣ របស់តុលាការខេត្តកណ្តាល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ចុះថ្ងៃទី១១ ខែ០៣ ឆ្នាំ២០០៣ របស់ឈ្មោះ........... ទុកជាត្រឹមត្រូវតាមទម្រង់ តែបដិសេធចោលដោយផ្ទុយពីគតិច្បាប់ ។

២-តម្កល់សាលក្រមលេខ ០៣(ក) ចុះថ្ងៃទី២៩-០១-២០០៣ ទុកជាមាន សុពលភាពតាមច្បាប់ដដែល ។

៣-សាលក្រមនេះ ប្រកាសជាសាធារណៈ កំបាំងមុខដើមបណ្តឹងទាស់ឈ្មោះ........... តែចាត់ទុកដូចជាចំពោះមុខ និងចំពោះមុខតំណាងចុងបណ្តឹងទាស់ឈ្មោះ.............។

បើកផ្លូវប្តឹងឧទ្ធរណ៍ពីរខែតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៣ របស់លោកមេធាវី ........... ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ១៤(ក) ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០០៣ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១១៨(ឈ) ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ : ,

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៤-០៦-២០០៣ របស់លោកមេធាវី........... ជាមេធាវីតំណាងឱ្យចុងចម្លើយទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៥-០៦-២០០៣ របស់លោកមេធាវី ............. ជាមេធាវីតំណាងឱ្យដើមចោទ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

៣-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ១៤(ក) ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៣ របស់តុលាការខេត្តកណ្តាល ទុកជាបានការ ។

៤-បង្គាប់ឱ្យចុងចម្លើយសងជម្ងឺចិត្តចំនួន៣០០$បទ(បីរយដុល្លាអាមេរិក)បន្ថែមលើសំណងជម្ងឺចិត្តដែតុលាការថ្នាក់ក្រោមបានសម្រេច ។

៥-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន៨៥០៛ចំណាយលើកិច្ចប្រគល់ដីកាកោះ៥.០០០៛និងចំណាយលើអាជ្ញាធរតុលាការចំនួន៥.០០០៛ សរុប ១៣.០០០៛ ។

៦-សាលដីកានេះ ជំនុំជំរះជាសាធារណៈនៅថ្ងៃទី១២-០៨-២០០៣ ចំពោះមុខមេធាវីតំណាងដើមចោទ កំបាំងមុខចុងចម្លើយ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៥-៨-២០០៣ កំបាំងមុខតំណាងដើមចោទ និងចុងចម្លើយ ។ បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លខ ១០ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៣ របស់ឈ្មោះលី សារិទ្ធ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១១៨(ឈ)ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៣ របស់ សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១៦៨(ឈ)ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ចុះថ្ងៃទី០៩-០៩-២០០៣ របស់ឈ្មោះលី សារិទ្ធ ទុកជា ត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីកំបាំងមុខលេខ១១៨(ឈ)ចុះថ្ងៃទី១៥-៨-២០០៣របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

៣-សាលដីកានេះ ជំនុំជំរះជាសាធារណៈនៅថ្ងៃទី១៤-១១-២០០៣ ចំពោះមុខមេធាវីតំណាងដើមចោទ ក៏បាំងមុខចុងចម្លើយនិងប្រកាសជាសាធារណៈនៅថ្ងៃទី១៨-១១-២០០៣ កំបាំងមុខគូក្តី តែចាត់ទុកជាចំពោះមុខ ។ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៨៥ ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ២០០៤ របស់លោក........... ជាមេធាវីការពារឱ្យចុងចម្លើយ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១៦៨(ឈ) ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី០៧ ខែមិនា ឆ្នាំ២០០៤ របស់ឈ្មោះលី សារិទ្ធ ។

បានឃើញសារណាតបចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៤ របស់ឈ្មោះចាំង ម៉េងស្រេង ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលាឧទ្ធរណ៍សម្រេចខុសឆ្គង ត្រង់ប្រាក់បន្ថែមលើសំណងជម្ងឺចិត្តដោយពុំមានមូលដ្ឋានច្បាស់លាស់ ។

បានស្តាប់ក្រឡាបញ្ជីអានសារណាការពាររបស់លគឈ ហៅលើ សារិទ្ធ ។

បានស្តាប់ក្រឡាបញ្ជីអានសារណាតបរបស់ឈ្មោះសសរ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក........... ជាមេធាវីការពារឱ្យលោកលីគង់ឈុន បានលើកឡើងថា : ដូចក្រឡាបញ្ជីបានអានសារណារបស់កូនក្តីខ្លួនរួចហើយ ឃើញថា តុលាការ ថ្នាក់ក្រោមធ្វើមិនត្រឹមត្រូវតាមនីតិវិធីទេ ឯសាលាឧទ្ធរណ៍សម្រេចខុសច្បាប់ទៀតពុំមានមូលដ្ឋានសោះ បែរជាសម្រេចបន្ថែមលើសំណងជម្ងឺចិត្ត ជាការខុសឆ្គងគួរបដិសេធចោល ឯការផ្ទេរសិទ្ធិទៀតសោត សូមឱ្យតុលាការកំពូលបង្វិលសំណុំរឿងឱ្យសាលាឧទ្ធរណ៍ជំនុំជំរះឡើងវិញ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធាវី ............. ជាតំណាងឱ្យលោក សុក សារ៉េតបានលើកឡើងថា : កូនក្តីខ្លួនបានធ្វើសារណាជូនមកតុលាការកំពូល ដូចក្រឡាបញ្ជីបានអានរួចមកហើយ ដើមចោទទទួលស្គាល់បំណុលកូនក្តីរួចហើយ ដើម្បីបញ្ចប់រឿងក្តីនេះ ខ្លួនតំណាងឱ្យសុកសារ៉េត សូមបោះបង់ចោលចំនួនប្រាក់ ៣០០ដុល្លាអាមេរិក ដែលសាលាឧទ្ធរណ៍បានសម្រេចបន្ថែម កន្លងមកនេះ សូមតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការចុះ លើកលែងការប្រាក់៣០០ដុល្លាអាមេរិក មិនទាមទារទេ ។ ឯការផ្ទេរសិទ្ធិមានឯកសារពីតុលាការថ្នាក់ក្រោមមកស្រាប់ ។

ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សារណារបស់គូភាគីនិងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីគូភាគី

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៨៥ ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ២០០៤ របស់ លោក........... មេធាវីឱ្យលោក លគឈ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបានដោយយោងតាមមាត្រា ១៤នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា នៅក្នុងសារណាការពាររបស់លោកលីគង់ឈុនហៅលីសារិទ្ធ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៤ ក៏ដូចជាចម្លើយនៅតុលាការថ្នាក់ក្រោមដែរ លោកលីគង់ឈុនបានទទួលស្គាល់ថានៅជំពាក់ប្រាក់លោកចាំង ម៉េងស្រេង និងលោកសសរចំនួន៤៧៤.៦៩៥ បាត (បួនសែនប្រាំពីរម៉ឺនបួនពាន់ប្រាំមួយរយកៅសិបប្រាំប៉ាត) ពិតប្រាកដមែន ។ ដូច្នេះចុងចម្លើយមានកាតព្វកិច្ចសងប្រាក់ដើមចោទតាមមាត្រា ២២.២៩និង ៥០ នៃក្រឹត្យច្បាប់លេខ ៣៨ក្រច ចុះថ្ងៃទី ២៥ ខែតុលា ឆ្នាំ១៩៨៨ ។

- យល់ឃើញថា ការដែលចុងចម្លើយលើកឡើងក្នុងសារណាថា លោកមិនសុខចិត្តក្នុង ការដែលសាលាឧទ្ធរណ៍សម្រេចអំពីការប្រាក់ក្នុងកិច្ចសន្យាលក់ទិញដីនោះ ក្នុងសារណាតបចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៤ របស់លោកចាំង ម៉េងស្រេង លោកបានសុំឈប់ទារការប្រាក់នៃប្រាក់ជំពាក់ ពីលោកលគឈ ហើយ ។ តុលាការកំពូលគប្បីអនុញ្ញាតតាមការព្រមព្រៀងនេះ ។

- យល់ឃើញថា ការមេធាវីចុងចម្លើយបានលើកឡើងថាការដែលសាលាឧទ្ធរណ៍សម្រេចឱ្យ ចុងចម្លើយសងប្រាក់សំណងជម្ងឺចិត្តបន្ថែមទៀតចំនួន៣០០ដុល្លាអាមេរិក បីរយអាមេរិក) ទៅលើទឹកប្រាក់ជម្ងឺចិត្តចំនួន១.០០០ដុល្លាដែលតុលាការខេត្តបានសម្រេចនោះ ពុំមានមូលដ្ឋាន ច្បាស់លាស់ទេ ។ ប៉ុន្តែមេធាវីដើមចោទបានសុំនៅពេលសវនាការនេះថា សុំមិនយកទេ ប្រាក់ជម្ងឺចិត្តបន្ថែមចំនួន ៣០០ដុល្លាអាមេរិកនេះ ដូច្នេះតុលាការកំពូលគប្បីអនុញ្ញាតតាមសុំ ។

- យល់ឃើញថា គូភាគី បានធ្វើសារណាជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមក ចូលរួមនាពេលសវនាការនេះទេ មានតែមេធាវីមកចូលរួម ដូច្នេះតុលាការកំពូលជំនុំជំរះ កំបាំងមុខ គូភាគី ចាត់ទុជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ១៦៨(ឈ) ចុះថ្ងៃទី១៨ ខែវិច្ឆិកាឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែគតិច្បាប់ត្រូវខ្លះខុសខ្លះ ។

**M ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីកំបាំងមុខគូក្តី ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ៨៥ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ២០០៤ របស់លោក ........... ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ខ្លះ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ១៦៨(ឈ) ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល លើកលែងតែចំណុចបន្ថែមសំណងជម្ងឺចិត្តចំនួន ៣០០ដុល្លាអាមេរិក និងការប្រាក់៥%ក្នុង១ឆ្នាំ ដែលត្រូវទុកជាមោឃៈ តាមសំណូមពររបស់គូភាគី។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០៛ ដែលលោកសសរបានបង់ទុកនៅតុលាការកំពូល គឺ :

-ពន្ធចុះបញ្ជីក្តីនឹងពន្ធហ្នឹងចំនួន៤.០០០រៀលប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀលសម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥០០៛ សរុប ១៩០០៛ ហើយតម្រូវឱ្យចុងចម្លើយសងប្រាក់ ១៩.០០០៛ នេះ ទៅដើមចោទវិញ ។

បង្គាប់ឱ្យចុងចម្លើយបង់ពន្ធសមាមាត្រលើប្រាក់ដែលត្រូវសងទៅដើមចោទ ។

៤-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០០៤ ។